របាយការណ៍ប្រចាំខែកក្កដា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ

## I.ស្ថានភាពមន្ទីរ

### ១-ការងាររដ្ឋបាល បុគ្គលិក

មន្ត្រីរាជការ ចំនួន ៥២ រូប ស្ត្រីចំនួន ០៤ រូប ក្នុងនោះមាន÷

- ប្រធានមន្ទីរ ០១ រូប និង អនុប្រធានមន្ទីរ ០២ រូប

-មន្ត្រីការិយាល័យចំណុះមន្ទីរសរុប÷ ៣២ រូប ស្រី ៤ រូបក្នុងនោះ មន្ត្រីកម្មសិក្សាថ្មីចំនួន ២ រូប ស្រី ០ រូប និង បុគ្គលិកបណ្តែតចំនួន ២ រូប ស្រី ០១ រូប

-មន្ត្រីការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ក្រុង សរុប÷ ១៧ រូប ស្រី ០ រូប

ការងារលិខិតស្នាមមាន÷

-បានទទួលលិខិតចូលតាមបណ្តាក្រសួង អង្គភាពនានា ចំនួន ៣៦ លិខិត

-បានទទួលលិខិតចូលពីក្រសួង សាមី ចំនួន ០៩ លិខិត

-លិខិតចេញទៅតាមបណ្តាអង្គភាព ស្ថាប័ននានា និងអង្គភាពក្រោមឱវាទចំនួន ៥៦ លិខិត

-បានធ្វើសំណើសុំពិនិត្យលើរបាយការណ៍ផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារ មន្ត្រីរាជការ ប្រចាំខែសីហា ឆ្នាំ ២០១៥ ជូនមន្ទីរមុខងារសាធារណៈខេត្ត

-បានធ្វើរបាយការណ៍វឌ្ឍនភាពសម្រាប់ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការ តាមប្រព័ន្ធធនាគារ សម្រាប់ខែកក្កដា ឆ្នាំ ២០១៥ ដែលមានក្នុងតារាងបៀវត្ស មានដូចខាងក្រោម ÷

| អង្គភាព | ចំនួនមន្ត្រីក្នុងតារាងបៀវត្ស | ចំនួនមន្ត្រីមានគណនីធនាគារ | ចំនួនមន្ត្រីមានបើកបៀវត្សតាមធនាគារ | ចំនួនមន្ត្រីគ្មានគណនីធនាគារ | ចំនួនមន្ត្រីជាក់ស្តែង |
|---|---|---|---|---|---|
| មន្ទីរអជប ខេត្ត | ៥២ | កាណាឌីយ៉ា=២៧ន<br>អេស៊ីលីដា= ២៥ ន | ៥២ | ០០ | ៥២ |

### ២-ការងារគណនេយ្យ និងហិរញ្ញវត្ថុ

| ជំពូក | បរិយាយ | ស្ថានភាពឥណ ទានគិតជារៀល | បណ្តាខែមុន | ចំណាយក្នុងខែ 07 | ចំណាយ បូកយោង | សមតុល្យ |
|---|---|---|---|---|---|---|
| ៦០ | ការទិញ | 154,700,000 | 5,119,050 | | 5,119,050 | 149,580,950 |
| ៦១ | សេវាខាងក្រៅ | 426,600,000 | 54,297,350 | 16,114,000 | 70,411,350 | 356,188,650 |
| ៦៣ | ពន្ធ និងអាករ | 3,000,000 | 0 | 0 | 0 | 3,000,000 |
| ៦៤ | បន្ទុកបុគ្គលិក | 412,600,000 | 202,597,410 | 2,022,000 | 204,619,410 | 207,980,590 |
| សរុបរួម | | 996,900,000 | 262,013,810 | 18,136,000 | 280,149,810 | 716,750,190 |

### ៣-ការងារផែនការ និង ស្ថិតិ

បូកសរុបរបាយការណ៍វឌ្ឍនភាពប្រចាំខែកក្កដា ឆ្នាំ ២០១៥

**៤-ការងារអធិការកិច្ច និងសវនកម្ម**

ថ្ងៃទី ១-២ ខែ កក្កដា ឆ្នាំ ២០១៥ គណៈប្រតិភូមួយក្រុមដឹកនាំដោយលោក **ពេជ្រ សេដ្ឋា** ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងបានចុះមកធ្វើអធិការកិច្ចនៅមន្ទីរ មានការចូលរួមដោយលោកប្រធានមន្ទីរ អនុប្រធានមន្ទីរ ព្រមទាំងប្រធាន អនុប្រធានការិយាល័យជំនាញចំណុះមន្ទីរទាំង ១០ ។

**៥-ការងារទំនាក់ទំនងសាធារណៈ និងកិច្ចប្រជុំផ្សេងៗ**

-លោក **មុំ ថៃម** ប្រធានមន្ទីរបានចូលរួមគ្រប់សកម្មភាពសង្គមនៅថ្នាក់ខេត្តបានចំនួន ១០ លើក

-លោក **តាន់ វាសនា** អនុប្រធានមន្ទីរបានចូលរួមគ្រប់សកម្មភាពសង្គមថ្នាក់ខេត្តបាន ០៦ លើក

-លោក **សេង ជាសុខ** អនុប្រធានមន្ទីរបានចូលរួមគ្រប់សកម្មភាពសង្គមថ្នាក់ខេត្តបាន ០៩ លើក

-ថ្ងៃទី១៧-០៧-១៥ មន្ទីរបានរៀបចំប្រជុំប្រចាំខែ ស្តីពីការងារបូកសរុបរបាយការណ៍ប្រចាំខែកក្កដា ក្រោមអធិបតីភាពលោកប្រធានមន្ទីរ ដោយមានការចូលរួមរបស់លោកអនុប្រធានមន្ទីរ និងប្រធាន អនុប្រធានការិយាល័យ និង មន្ត្រីរាជការទាំងអស់ក្នុងមន្ទីរ

II. **សកម្មភាពតាមវិស័យ**

**១-ការងារផ្លូវជនបទ**( ថវិកាកម្មវិធី)

-ក្រុមការងារសារពើភ័ណ្ឌផ្លូវមន្ទីរបានចុះស្រង់ទិន្នន័យផ្លូវជនបទប្រភេទ៤ ដែលនៅសេសសល់ និងធ្វើបច្ចុប្បន្នភាពខ្សែផ្លូវស្ថិតក្នុងស្រុក កំពង់ស្វាយ ប្រាសាទសំបូរ សម្រេចបាន÷

ក.ចុះស្រង់ទិន្នន័យផ្លូវជនបទ ប្រភេទ ៤ បាន ១៧ ខ្សែ ប្រវែងសរុប ៣៧,៤៣២ គ.ម ស្ថិតនៅឃុំកំពង់ស្វាយ ត្រពាំងឫស្សី និងឃុំជ័យ ស្រុក កំពង់ស្វាយ

ខ.ធ្វើបច្ចុប្បន្នភាពខ្សែផ្លូវបានចំនួន ៣ ខ្សែ ប្រវែងសរុប ១៤,៧ គ.ម ស្ថិតនៅស្រុកប្រាសាទសំបូរ

-ត្រៀមរៀបចំអនុវត្តគម្រោងសង្គ្រោះបន្ទាន់ ផ្លូវជ័យជំនះ ដល់ ស្វាយកាល់ ប្រវែង ៣,២គម នៅឃុំកកោះ ស្រុកសន្ទុក

-ជូន **ឯកឧត្តម ហួត សារឹម** អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ចុះពិនិត្យទីតាំងសាងសង់ផ្លូវក្រាលក្រួសក្រហម ០១ ខ្សែ នៅឃុំមានរិទ្ធិ ស្រុកសណ្តាន់ និងពិនិត្យទីតាំងស្ពានអូរតាឆុង នៅឃុំស្រើង ស្រុកប្រាសាទសំបូរ

-បានជូនក្រុមហ៊ុន ពិនិត្យទីតាំងផ្លូវដែលត្រូវជួសជុលខួប០២ខ្សែ ប្រវែងសរុប ៧,៩៥ គ.ម នៅឃុំកំពង់ស្វាយ និងឃុំជ័យ ស្រុកកំពង់ស្វាយ (ថវិកាកម្មវិធី) របស់មន្ទីរ ឆ្នាំ២០១៥

**២-ការងារផ្គត់ផ្គង់ទឹកស្អាតជនបទ**( ថវិកាកម្មវិធី)

-លើកផែនការសកម្មភាពប្រចាំខែកក្កដា ឆ្នាំ ២០១៥÷

- ចុះស្រង់ទិន្នន័យ និងត្រួតពិនិត្យស្ថានភាពអណ្តូង នៅឃុំស្វយោង ស្រុកបារាយណ៍
- ចុះជ្រើសរើសទីតាំងអណ្តូងសម្រាប់ការជួសជុលឆ្នាំ២០១៥ នៅឃុំកកោះ ស្រុកសន្ទុក

-លើកផែនការថវិការសម្រាប់គម្រោងជួសជុលអណ្តូងលូចម្រុះ ចំនួន ១០០ អណ្តូង សម្រាប់ឆ្នាំ ២០១៦ ដែលមាន ០៤ ស្រុក ០៧ ឃុំ ២៣ ភូមិ÷ស្រុកស្ទោង ០៣ ឃុំ ស្មើ ៣២ អណ្តូង មាន ០៦ ភូមិ ស្រុកកំពង់

ស្វាយ ០២ ឃុំស្មើ ៣៥ អណ្តូង មាន ០៧ ភូមិ ស្រុកប្រាសាទសំបូរ ០១ ឃុំស្មើ ១៥ អណ្តូង មាន ០៥ ភូមិនិង ស្រុកសណ្តាន់ ០១ ឃុំស្មើ ១៨ អណ្តូង មាន ០៥ ភូមិ

-លើកផែនការថវិកាសម្រាប់គម្រោង ផែនការ សាងសង់អណ្តូងថ្មី និងជួសជុលអណ្តូង ចំនួន ១០០ កន្លែង ក្នុងខេត្តកំពង់ធំ ប្រចាំឆ្នាំ ២០១៦÷

- ការងារសាងសង់អណ្តូងថ្មី ស្នប់អាហ្វ្រិដេស ចំនួន ១៤ អណ្តូង
- ការងារជួសជុលមាន ៨៦ អណ្តូង ៣៣ អណ្តូងសម្រាប់ស្នប់អាហ្វ្រិដេស ៥៣ អណ្តូងសម្រាប់អណ្តូងលូចម្រុះ

-បានធ្វើបច្ចុប្បន្នភាពទិន្នន័យអណ្តូងគ្រប់ប្រភេទ តាមបណ្តាស្រុកឆ្នាំ ២០១៥

-បានផ្តល់ដំណឹងទៅការិយាល័យស្រុក ក្រុង ដើម្បីប្រមូលទិន្នន័យ ស្តីពីផលប៉ះពាល់ពីគ្រោះរាំងស្ងួតដល់ម្ចាស់អណ្តូងក្នុងខេត្តកំពង់ធំ

-បានចុះទៅប្រមូលទិន្នន័យ និងត្រួតពិនិត្យស្ថានភាពអណ្តូង នៅភូមិរស្មីរំដោះ ឃុំស្វាយយោង ស្រុកបារាយណ៍ ជាលទ្ធផលពីលោកមេភូមិ គឺ÷ប្រជាជនសរុបស្មើ ៦០៦ នាក់ ស្រី ៣៣៧ នាក់ គ្រួសារសរុបស្មើ ១៨១ ស្មើ ១២៣ ខ្នងផ្ទះ បង្គន់សរុប ៧៨ បង្គន់ ធុងចម្រោះសរុប ៧ ធុង អណ្តូងសរុប ១០៧ អណ្តូង (អាហ្វ្រិដេស ២ លូចម្រុះចំនួន ៤៤ និង អណ្តូងលូចំនួន ៦១)។

**៣-ការងារសុខភាពអនាម័យជនបទ**

បានចុះប្រមូលពតិមានទិន្នន័យបង្គន់អនាម័យ បានចំនួន ៧ ភូមិ ក្នុងសង្កាត់កំពង់ធំ ក្រុងស្ទឹងសែន លទ្ធផលសរុបបង្គន់ចាក់ទឹកមានចំនួន ៥៤០ បង្គន់ ។

**៤-ការងារអភិវឌ្ឍន៍សហគមន៍** (ថវិកាកម្មវិធី) (គ្មានសកម្មភាព)

**៥-ការងារបណ្តុះបណ្តាល និង ស្រាវជ្រាវ** (សកម្មភាពអភិវឌ្ឍន៍ធនធានមនុស្សក្នុងប្រទេស)

| ល.រ | ប្រភេទវគ្គ | | | | ឈ្មោះមន្ត្រីចូលរួម | តួនាទី | ខ្លឹមសារ | រយះពេល | ចំនួនថ្ងៃ | ទីកន្លែង | អង្គភាពរៀបចំ |
|---|---|---|---|---|---|---|---|---|---|---|---|
| | ប | ស | ទ | ស.រ | | | | | | | |
| 1 | | ស | | | 1-លោក មុំ ចែម<br>2-លោក តាន់ វាសនា<br>3-លោក ប្រាក់ មុត<br>4-លោក សរ វឌ្ឍនី<br>5-លោក ស៊ុន ជួត<br>6-លោក ជុំយ វ៉ង់<br>7-លោក ប្រាក់ សុវណ្ណ<br>8-លោក ម៉ិល សម៉យ<br>9-លោក ង៉ែត ពលរិទ្ធិ<br>10-លោក ព្រហ្ម ឆោម | ប្រធាន អនុប្រធានមន្ទីរ- ប្រធានការិ-មន្ទីរ និង ស្រុក | ផ្សព្វផ្សាយគោលនយោបាយ ស្តីពី ការអភិវឌ្ឍន៍ជនជាតិភាគតិច ដំណើរការ និតិវិធីនៃការកំណត់អត្តសញ្ញាណចុះបញ្ជីសហគមន៍ជនជាតិភាគតិចជានិតិបុគ្គល | 24/06/15 | 1 | កំពង់ធំ | MRD/DPA/ILO |
| 2 | | ស | | | លោក សេង ជាសុខ | អនុប្រធាន មន្ទីរ | ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ | 23-25/06/15 | 3 | កំពង់ធំ | កាកបាតក្រហមខេត្ត |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 3 | | ស | | | លោក ស៊ីន វុទ្ធា | ប្រធានការិ- | តម្រង់ទិសស្តីពីការអនុវត្តសាកល្បងគោលការណ៍ណែនាំអំពីការបំពេញលក្ខខ័ណ្ឌទឹកស្អាត និងអនាម័យនៅ សាលាបឋមសិក្សា | 13/07/15 | 1 | កំពង់ធំ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត |

**៦-ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ** (គ្មានសកម្មភាព)

**៧-ការងារជនជាតិដើមភាគតិច** (គ្មានសកម្មភាព)

**៨-ការងារ** Gender÷ (គ្មានសកម្មភាព)

**៩-អង្គការក្នុង និង ក្រៅរដ្ឋាភិបាលក្រោមកិច្ចសហការជាមួយមន្ទីរ**

៩.១.អង្គការ iDE ÷(គ្មានរបាយការណ៍)

៩.២.អង្គការស្អាតកម្ពុជា ÷ស្រុក បារាយណ៍ និង ស្រុក សន្ទុក (គ្មានរបាយការណ៍)

៩.៣.អង្គការ CARITAS ÷(គ្មានរបាយការណ៍)

៩.៤.អង្គការ សកម្មភាពដើម្បីអភិវឌ្ឍន៍ (AFD) (គ្មានរបាយការណ៍)

៩.៥. CWS (គ្មានរបាយការណ៍)

៩.៦.អង្គការ Moslim Aid (គ្មានរបាយការណ៍)

**៩.៧.** WVC ÷ បានសហការជាមួយមន្ត្រីមន្ទីរ ទទួលបានលទ្ធផលដូចខាងក្រោម÷

-ថ្ងៃទី ២៥ខែ មិថុនា ឆ្នាំ ២០១៥ មន្ត្រីជំនាញការិយាល័យសុខភាពចំនួន ០១ រូប បានចូលរួមសហការជាមួយអង្គការទស្សនៈពិភពលោកប្រចាំខេត្តកំពង់ធំ និងមានការជួយឧបត្ថម្ភគាំទ្រថវិកាពីអង្គការទស្សនៈពិភពលោកប្រចាំតំបន់អភិវឌ្ឍន៍ស្រុកប្រាសាទបល្ល័ង្គ និងស្រុកស្ទោង បានដំណើរការរៀបចំប្រារព្ធពិធីអបអរសាទរប្រកាសលទ្ធផល "សហគមន៍បញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល" មានចំនួនពីរភូមិ គឺនៅភូមិបុស្សធំ ឃុំក្រយា ស្រុក ប្រាសាទបល្ល័ង្គ និង ភូមិថ្លោច ឃុំ ចំណារលើ ស្រុក ស្ទោង ក្រោមអធិបតីភាព **ឯកឧត្តម ហួន វ៉ាន់និត** អភិបាលរងខេត្តកំពង់ធំ លោក **តាន់ វាសនា** អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត លោក **ពេញ កែវ** អភិបាលរងស្រុកប្រាសាទបល្ល័ង្គ លោកស្រី **ហ៊ុល ឡៃហ៊ាង** អភិបាលរងស្រុកស្ទោង និង លោក **អាន លីហ៉ រ និង** លោកស្រី **ច័ន្ទ សុភា** តំណាងអង្គការទស្សនៈពិភពលោក ដោយមានការចូលរួមពីក្រុមប្រឹក្សាឃុំ ជនសកម្មអនាម័យភូមិ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋសរុបចំនួន ៤១៧ នាក់ ស្រី ២៧០ នាក់ ។
ក្នុងពិធីនេះដែរក៏មានការប្រគល់ជូននូវលិខិតសរសើរ ដល់តំណាងភូមិបុស្សធំ និងភូមិថ្លោចដែលបានបញ្ឈប់បន្ទោរបង់ពាសវាលពាសកាល ១០០%និងកាដូអនុស្សាវរីយ៍ដល់ក្រុមសកម្មអនាម័យភូមិផងដែរ។

-ថ្ងៃទី ១៧-០៧-១៥ លោកអនុប្រធានមន្ទីរ និងមន្ត្រីជំនាញការិយាល័យសុខភាពចំនួន ០១ រូប បានចូលរួមវាយតម្លៃភូមិបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល បានចំនួនមួយភូមិ គឺនៅភូមិក្រសាំងជ្រុំជើង ឃុំសំព្រោជ ស្រុកស្ទោង សមាសភាពចូលរួមវាយតម្លៃរបស់គណៈកម្មការអនាម័យភូមិមានចំនួន ១៩ នាក់ និងអ្នកសម្របសម្រួលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ០២ នាក់ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ចំនួន ០១ នាក់ និងតំណាងអង្គការទស្សនៈពិភពលោកចំនួន ០១ នាក់

**៩.៨.អង្គការ ពន្លឺអភិវឌ្ឍន៍** (APA) (គ្មានរបាយការណ៍)

៩.៩.អង្គការ ស្រែខ្មែរ ÷(គ្មានរបាយការណ៍)

៩.១០.អង្គការ ADRA (គ្មានរបាយការណ៍)

៩.១១.អង្គការ HOM (គ្មានរបាយការណ៍)

៩.១២.អង្គការ ESSD (គ្មានរបាយការណ៍)

៩.១៣.អង្គការ ទឹកស្អាត ១០០១ (គ្មានរបាយការណ៍)

**១០-កម្មវិធី និង គម្រោង**

**១០.១-គម្រោងផ្គត់ផ្គង់ទឹកនិងអនាម័យជនបទទី ២** (RWSSSP-2) (មន្ត្រីចំនួន ០៣ នាក់)

គម្រោងបានបញ្ចប់កិច្ចសន្យាជាមួយមន្ត្រីចំនួន ៨ នាក់ នៅសល់មន្ត្រីចំនួន ៥ នាក់ ដែលនឹងបញ្ចប់កិច្ចសន្យានៅដំណាច់ឆ្នាំ ២០១៥។

**១០.២-គម្រោងផ្លូវក្រាលកៅស៊ូ** (RRIP-2) (មន្ត្រីចំនួន ០៤ នាក់) (គ្មានសកម្មភាព)

**១០.៣-កម្មវិធី** WFP (ផ្លូវជីស)(មន្ត្រីចំនួន ០៤ នាក់) ការងារស្បៀងសម្រាប់ទ្រព្យធន

| ទីតាំងគម្រោង | | | ប្រភេទ គម្រោង | ប្រវែង (ម) | អ្នកចូលរួម | | ស្បៀង(តោន) | | លទ្ធផល (%) |
|---|---|---|---|---|---|---|---|---|---|
| ស្រុក | ឃុំ | ភូមិ | | | ស្រី | សរុប | ស្នើសុំ | អនុម័ត | |
| ប្រាសាទបល្ល័ង្គ | សាលាវិស័យ | ចំណារ | ទំនប់សង់ថ្មី | 898 | 96 | 385 | 10.460 | 10.460 | ១០០% |
| ប្រាសាទបល្ល័ង្គ | សាលាវិស័យ | បុស្ស ស្រមោច | ទំនប់សង់ថ្មី | 724 | 87 | 380 | 7.210 | 7.210 | ១០០% |
| កំពង់ស្វាយ | ក្តីដូង | ពាមគ្រែង | ផ្លូវលំសង់ថ្មី | 1.157 | 154 | 500 | 19.390 | 19.390 | ១០០% |
| ស្ទោង | សំព្រោជ | ត្រាចជ្រុំ | ផ្លូវលំសង់ថ្មី | 650 | 226 | 945 | 12.150 | 12.150 | ១០០% |
| ប្រាសាទសំបូរ | ឈូក | ត្រពាំងសាលា | ផ្លូវលំជួសជុល | 683 | 164 | 665 | 10.530 | 10.530 | Post |
| ប្រាសាទសំបូរ | សំបូរ | កូនក្អែក | ផ្លូវលំសង់ថ្មី | 1.107 | 380 | 1535 | 19.520 | 19.520 | ១០០% |
| ប្រាសាទសំបូរ | ស្រើង | ស្វាយ | ទំនប់សង់ថ្មី | 1.111 | 131 | 515 | 17.060 | 17.060 | ១០០% |
| ប្រាសាទសំបូរ | ស្រើង | ទំនប់ | ទំនប់សង់ថ្មី | 1.724 | 226 | 1260 | 23.630 | 23.630 | Post |
| ស្ទឹងសែន | ស្រយ៉ូវ | ស្រយ៉ូវជើង | ផ្លូវលំសង់ថ្មី | 961 | 236 | 590 | 19.250 | 19.250 | ១០០% |
| សន្ទុក | ត្បូងក្រពើ | ចុងដា | ផ្លូវលំសង់ថ្មី | 781 | 139 | 615 | 17.220 | 17.220 | ១០០% |
| សន្ទុក | ត្បូងក្រពើ | កាលមេឃ | ផ្លូវលំសង់ថ្មី | 1.231 | 184 | 550 | 22.720 | 22.720 | ១០០% |
| ស្ទោង | សំព្រោជ | ស្លាក់ក្រាញ់ | ផ្លូវលំសង់ថ្មី | 1.322 | 224 | 890 | 24.760 | 24.760 | ១០០% |
| កំពង់ស្វាយ | កំពង់ស្វាយ | ត្នោត | ផ្លូវលំសង់ថ្មី | 646 | 192 | 570 | 16.910 | 16.910 | ១០០% |
| កំពង់ស្វាយ | កំពង់ស្វាយ | ឥន្ទកុមារ | ផ្លូវលំសង់ថ្មី | 1.050 | 215 | 645 | 19.880 | 19.880 | Post |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ស្ទោង | ចំណាក្រោម | ចំណាក់ | ផ្លូវលំជួសជុល | 509 | 93 | 445 | 10.890 | 10.890 | លុបចោល |
| កំពង់ស្វាយ | ត្រពាំងឫស្សី | រំមាំងងាប់ | ផ្លូវលំសង់ថ្មី | 1.103 | 198 | 470 | 19.030 | 19.030 | Post |
| កំពង់ស្វាយ | នីពេជ | ដូនឈូក | ផ្លូវលំសង់ថ្មី | 1.150 | 204 | 500 | 18.260 | 18.260 | 80% |
| កំពង់ស្វាយ | ក្ដីដូង | ក្ដីដូង | ផ្លូវលំសង់ថ្មី | 735 | 145 | 435 | 13.380 | 13.380 | Post |
| ប្រាសាទសំបូរ | សំបូរ | សំបូរ | ផ្លូវលំសង់ថ្មី | 816 | 201 | 650 | 12.020 | 12.020 | ១០០% |
| ស្ទោង | បន្ទាយស្ទោង | បវែង | ទំនប់ស្ទាក់ទឹក | 836 | 132 | 480 | 12.580 | 12.580 | Post |
| ស្ទឹងសែន | ស្រយ៉ូវ | ស្រយ៉ូវត្បូង | ផ្លូវលំសង់ថ្មី | 620 | 164 | 400 | 12.110 | 12.110 | Post |
| កំពង់ស្វាយ | កំពង់ស្វាយ | ព្រៃព្រះ | ផ្លូវលំជួសជុល | 667 | 209 | 550 | 9.630 | 9.630 | ៨០% |
| ប្រាសាទសំបូរ | តាំងក្រសៅ | សូរិយា | ផ្លូវលំជួសជុល | 704 | 51 | 205 | 10.170 | 10.170 | ១០០% |
| កំពង់ស្វាយ | ជ័យ | ត្រពាំងអារ៉ក្ស ១ | ទំនប់សង់ថ្មី | 929 | 184 | 450 | 16.250 | 16.250 | ១០០% |
| កំពង់ស្វាយ | ជ័យ | ត្រពាំងអារ៉ក្ស ២ | ទំនប់សង់ថ្មី | 895 | 180 | 415 | 12.330 | 12.330 | ១០០% |
| កំពង់ស្វាយ | ជ័យ | តាធាវ | ប្រឡាយសង់ថ្មី | 670 | 120 | 270 | 8.820 | 8.820 | ៨០% |
| ស្ទោង | បន្ទាយស្ទោង | ដូនប៉ុក | ទំនប់ស្ទាក់ទឹកថ្មី | 1.674 | 164 | 410 | 24.800 | 24.800 | ៩០% |
| កំពង់ស្វាយ | ត្បែង | ពោធិ | ផ្លូវលំជួសជុល | 914 | 197 | 750 | 17.470 | 17.470 | ១០០% |
| កំពង់ស្វាយ | ត្រពាំងឫស្សី | ត្រពាំងថ្ម | ផ្លូវលំសង់ថ្មី | 1.008 | 284 | 600 | 15.150 | 15.150 | ១០០% |
| កំពង់ស្វាយ | ត្រពាំងឫស្សី | ត្រពាំងព្រលិត | ផ្លូវលំជួសជុល | 1,533 | 176 | 675 | 11.400 | 11.400 | ៨០% |
| កំពង់ស្វាយ | កំពង់ស្វាយ | អន្លង់ក្រសាំង | ផ្លូវលំសង់ថ្មី | 334 | 86 | 215 | 23.000 | 23.000 | ៨០% |
| សរុប | | | | 29,142 | 5,442 | 17,965 | 487.980 | 487.980 | |

**១០.៤-គម្រោងអភិវឌ្ឍន៍ជនបទវាលទំនាបបឹងទន្លេសាប** (មន្ត្រីចំនួន ៥ នាក់)(គ្មានសកម្មភាព)

**១០.៥-គម្រោង** ( RIP-III) (មន្ត្រីចំនួន ០៤ នាក់ )

ចុះសិក្សាខ្សែផ្លូវលើកគម្រោងសម្រាប់ថៃទាំខួប ឆ្នាំ ២០១៦ បានចំនួន ១០ ខ្សែ មានប្រវែងសរុប ៧២,២ គ.ម នៅក្នុងស្រុកបារាយណ៍ សន្ទុកប្រាសាទសំបូរ កំពង់ស្វាយ និងក្រុងស្ទឹងសែន ។

**១០.៦-កម្មវិធី ទឹកស្អាត និង អនាម័យ** ( UNICEF) (មន្ត្រីចំនួន ៤ នាក់)(គ្មានសកម្មភាព)

**១០.៧-កម្មវិធីកំចាត់មីនខេត្ត** (MAPU ) (មន្ត្រីចំនួន ០១ នាក់ ) (គ្មានសកម្មភាព)

**១០.៨-គម្រោង** (LASED) (មន្ត្រីចំនួន ០២ នាក់ ) (គ្មានសកម្មភាព)

**១០.៩-គម្រោងស្បៀងបន្ទាន់** (Cash for Work)(មន្ត្រីចំនួន ០៤ នាក់ )

-គម្រោងក្រាលក្រួសក្រហមចំនួន ២ ខ្សែគឺ ១.ពីភូមិ និមិត្ត ដល់ ភូមិ ផ្លូង ឃុំទីពោ ស្រុកសន្ទុក ប្រវែង ៤,៣៧៧ គ.ម អនុវត្តបាន ៨០%។ ២.ផ្លូវ ភូមិ រលាក់ពេន ឃុំទ្រៀល ស្រុកបារាយណ៍ ប្រវែង ២,៧ គ.ម អនុវត្តបាន ៨០%

-គម្រោងសាច់ប្រាក់ពលកម្ម ការងារជីស នៅភូមិ ខ្សាច់ជីរស់ ឃុំ កំពង់គោ ស្រុក កំពង់ស្វាយ ចំនួន ១ ខ្សែ ប្រវែង ១,៥១ គ.ម សម្រេចបាន ១០០%

**១០.១០-គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ** (មន្ត្រីចំនួន ០៣ នាក់)

បានចុះតាមដានការងារនៅភូមិ គោលដៅគម្រោងចំនួន ៣ លើក

## III.**ទិសដៅបន្ត**

-នឹងសាងសង់ផ្លូវជនបទក្រាលកៅស៊ូ DBST ជំហានទី ២ ប្រមាណជា ១២២,៧ គ.ម ក្នុងនោះគឺ ÷

- ផ្លូវពីទ្រា ដល់សាគ្រាម ប្រវែង ៤៩ គ.ម ស្រុក ស្ទោង និងប្រាសាទបល្ល័ង្គ
- ផ្លូវពីតារាម ដល់ ស្នោញ ប្រវែង ២០ គ.ម ស្រុកប្រាសាទបល្ល័ង្គ និងស្រុក កំពង់ស្វាយ
- ផ្លូវពីកំពង់ស្បូវ ដល់ ងន ប្រវែង២០,៤ គ.ម ស្រុកប្រាសាទសំបូរ និងស្រុកសណ្តាន់
- ផ្លូវពីសាលាវិស័យ ដល់ ក្រយា ប្រវែង ៣២,២ គ.ម ស្រុកប្រាសាទបល្ល័ង្គ

- ថែទាំផ្លូវជាលក្ខណៈខួប ផ្លូវក្រាលគ្រួសក្រហម ចំនួន ០៣ ខ្សែ ប្រវែង ១៥ គ.ម ស្ថិត ក្នុងឃុំត្រពាំងឫស្សី និង ឃុំ ជ័យ ស្រុកកំពង់ស្វាយ និង ឃុំចុងដូង ស្រុកបារាយណ៍ (គម្រោង TSLRDP)

-អង្គការ ADRA គ្រោង ២០១៥ នឹងផ្តល់បង្គន់អនាម័យចំនួន ២០០ បង្គន់ និងផ្តល់ធុងចម្រោះទឹកស្អាត ៤៦០ ធុង នៅស្រុកបារាយណ៍ និងស្រុកសន្ទុក

## IV. **សំណូមពរ**

-រិះរកមធ្យោបាយណាដើម្បីឲ្យសហគមន៍ចូលរួមសាងសង់ និង ទិញបង្គន់អនាម័យយកទៅប្រើប្រាស់

-ស្នើសុំថវិកាទៅតាមផែនការសម្រាប់ឆ្នាំ ២០១៥ ឲ្យបានទាន់ពេលវេលា

-គួរមានប្រាក់ឧបត្ថម្ភដល់សមាជិក គ.អ.ភ

-ពង្រឹងការអនុវត្តតួនាទី ភារកិច្ចការិយាល័យជំនាញ និង ក្រុង ស្រុក

-ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការ ក្នុងការបំពេញការងារប្រចាំថ្ងៃ

-ឲ្យមានការបណ្តុះបណ្តាលមន្ត្រីបន្ថែមទាំងរយៈពេលខ្លី វែង

-ស្នើសុំឥណទានបន្ថែមសម្រាប់គម្រោងឥណទានក្រសួង អជប ពីព្រោះអតិថិជនត្រូវការខ្ចីច្រើន

ប្រធានមន្ទីរ